Australian Government
Department of Human Services

# Paid Parental Leave scheme សម្រាប់ឪពុកម្តាយ

នៅពេលលោកអ្នកមានកូនថ្មីណាម្នាក់ចូលមកក្នុងគ្រួសាររបស់លោកអ្នក ហើយចង់យកពេលឈប់សម្រាកពីការងារ គឺជាការល្អដែលដឹងថាលោកអ្នកអាចទទួលបានការផ្គត់ផ្គង់ប្រាក់មួយចំនួន។

Paid Parental Leave scheme ជួយឪពុកម្តាយដែលធ្វើការឲ្យបានឈប់សម្រាកពីការងារដើម្បីមើលថែទារកទើបនឹងកើត ឬក្មេងដែលយកមកចិញ្ចឹមនៅពេលថ្មីៗ។ Australian Government ជាអ្នកផ្តល់ប្រាក់សម្រាប់គម្រោងការនេះ។ អ្នកធ្វើការងារគ្រប់ប្រភេទអាចមានសិទ្ធិទទួលបាន ដោយមានរួមទាំងអ្នកធ្វើការងារពេញម៉ោង  ការងារពុំពេញម៉ោង អ្នកធ្វើការងារម្តងម្កាល អ្នកធ្វើការងារតាមរដូវ អ្នកធ្វើការងារតាមកិច្ចសន្យា និងអ្នកធ្វើការងារដោយខ្លួនឯងផងដែរ។

មានប្រាក់ជំនួយពីរប្រភេទដែលអាចផ្តល់ជូនក្រោមគម្រោងការនេះ -  Parental Leave Pay សម្រាប់អ្នកមើលថែចម្បងរបស់ក្មេង និង Dad and Partner Pay ដែលមានផ្តល់សម្រាប់ឪពុក ឬដៃគូ (មានរួមទាំងឪពុកម្តាយចិញ្ចឹម និងគូស្រករមានភេទដូចគ្នាផងដែរ) ចាប់ពីថ្ងៃទី១ មករា ឆ្នាំ២០១៣ តទៅ។

## Parental Leave Pay

ក្នុងភាពជាអ្នកមើលថែចម្បងរបស់ក្មេង  លោកអ្នកអាចទទួលបាន  Parental Leave Pay រហូតដល់ទៅ១៨អាទិត្យ តាមអត្រានៃ National Minimum Wage។ អ្នកមើលថែចម្បងគឺជាអ្នកដែល បំពេញតាមសេចក្តីត្រូវការភាគច្រើននៃផ្នែករាងកាយរបស់ក្មេង។ Parental Leave Pay គឺជាប្រាក់ដែលត្រូវបង់ពន្ធ។

## សូមឆែកមើលក្រែងលោលោកអ្នកអាចមានសិទ្ធិទទួលបាន Parental Leave Pay

លោកអ្នកប្រហែលជាអាចទទួលបាន Parental Leave Pay ប្រសិនបើលោកអ្នក:

- ជាអ្នកមើលថែចម្បងរបស់ទារកទើបនឹងកើត ឬក្មេងដែលយកមកចិញ្ចឹមនៅពេលថ្មីៗ (តាមធម្មតាគឺម្តាយ)។
- បំពេញតាមតម្រូវការនៃភាពជាពលរដ្ឋរស់នៅក្នុងប្រទេសចាប់តាំងពីថ្ងៃដែលក្មេងនោះចូលមករស់នៅក្រោមការមើលថែរបស់លោកអ្នករហូតដល់ចប់ Paid Parental Leave periodរបស់លោកអ្នក។
- បំពេញតាមតម្រូវការនៃតេស្តការងារដែលតម្រូវឲ្យលោកអ្នកធ្វើការបាន:
  - យ៉ាងហោចណាស់ចំនួន១០ខែ ក្នុងពេល១៣ខែមុនកំណើត ឬយកក្មេងមកចិញ្ចឹម
  - យ៉ាងហោចណាស់ចំនួន៣៣០ម៉ោង ក្នុងកំឡុងពេល១០ខែនោះ (គឺត្រឹមតែ១ថ្ងៃប៉ុណ្ណោះ ក្នុង១អាទិត្យ) ដោយពុំមានពេលចន្លោះច្រើនជាងប្រាំបីអាទិត្យ រវាងពីរថ្ងៃធ្វើការបន្តបន្ទាប់គ្នាឡើយ
- មានប្រាក់ចំណូលត្រូវបង់ពន្ធដារដែលបានកែតម្រូវក្នុងបុគ្គលម្នាក់ៗចំនួន $150 000 ឬតិចជាង ក្នុងឆ្នាំសារពើពន្ធមុនថ្ងៃ កំណើត ឬថ្ងៃយកកូនមកចិញ្ចឹម ឬថ្ងៃដែលលោកអ្នកទាមទារ (មួយណាក៏បានឲ្យតែកើតមានមុន)និង

- កំពុងឈប់សម្រាកពីការងារ ឬពុំធ្វើការចាប់ពីពេលដែលលោកអ្នកក្លាយជាអ្នកមើលថែចម្បងរបស់ក្មេង រហូតដល់ចប់អំឡុងពេល Paid Parental Leave period របស់លោកអ្នក។

**កំណត់សំគាល់:** លោកអ្នកប្រហែលជានៅតែអាចមានសិទ្ធិទទួលបាន Parental Leave Pay ក្នុងករណីនៃទារកស្លាប់ក្នុងពោះ ឬទារកស្លាប់។

# ពេលដែលលោកអ្នកអាចទទួលបាន Parental Leave Pay

អំឡុងពេល Paid Parental Leave (រហូតដល់១៨អាទិត្យ) របស់លោកអ្នកអាចចាប់ផ្តើមពីថ្ងៃដែលកូនរបស់លោកអ្នកកើតមក ឬយកកូនមកចិញ្ចឹម ឬនៅថ្ងៃក្រោយមកទៀត។ នៅពេលលោកអ្នកដាក់ពាក្យសុំអំឡុងពេលនេះ លោកអ្នកអាចប្រាប់ឲ្យយើងដឹងថាពេលណាលោកអ្នកចង់ឲ្យអំឡុងពេលនេះចាប់ផ្តើម។ លោកអ្នកត្រូវទទួលយក Parental Leave Pay ក្នុងអំឡុងពេលជាប់បន្តបន្ទាប់គ្នាមួយ ហើយប្រាក់នេះត្រូវតែបានបើកគ្រប់ចំនួនក្នុងរង្វង់ពេល៥២អាទិត្យ បន្ទាប់ពីកំណើតកូន ឬការយកកូនមកចិញ្ចឹម។ ដើម្បីទទួលប្រាក់ Parental Leave Pay ចំនួន១៨អាទិត្យឲ្យបានពេញ ថ្ងៃចាប់ផ្តើមរបស់លោកអ្នកត្រូវនៅស្ថិតនៅក្នុងរង្វង់ពេល៣៤អាទិត្យបន្ទាប់ពីកំណើតកូន ឬការយកកូនមកចិញ្ចឹម។

គឺជាការសំខាន់ដែលត្រូវដឹងថា ថ្ងៃដែលលោកអ្នកប្រាប់យើងដើម្បីចាប់ផ្តើមទទួលប្រាក់របស់លោកអ្នក ពុំមែនជាថ្ងៃទទួលប្រាក់លើកទីមួយរបស់លោកអ្នកកើតមានឡើងនោះឡើយ ហើយដើម្បីឲ្យប្រាក់របស់លោកអ្នកចាប់ផ្តើម លោកអ្នកត្រូវផ្តល់ឲ្យយើងនូវភស្តុតាងនៃកំណើតកូន ឬការយកកូន មកចិញ្ចឹមរបស់លោកអ្នក។

លោកអ្នកត្រូវឈប់សម្រាកពីការងារ ឬពុំធ្វើការឡើយចាប់ពីពេលដែលលោកអ្នកក្លាយជាអ្នកមើលថែចម្បងរបស់ក្មេង រហូតដល់ទីបញ្ចប់នៃអំឡុងពេល Paid Parental Leave។ លោកអ្នកគួររៀបចំការឈប់សម្រាកពីការងាររបស់លោកអ្នកជាមួយនិយោជករបស់លោកអ្នកឲ្យបានយ៉ាងហោចណាស់នៅពេល១០ អាទិត្យ មុនពេលលោកអ្នកចង់យកការឈប់សម្រាកពីការងារ។

# របៀបដែលលោកអ្នកនឹងទទួលបាន Parental Leave Pay

ទោះបីរដ្ឋាភិបាលជាអ្នកផ្តល់ប្រាក់ Parental Leave Pay ក៏ដោយ លោកអ្នកទំនងជាបានទទួលប្រាក់នេះពីនិយោជករបស់លោកអ្នក ចេញពីពេលបើកប្រាក់បៀវត្សរ៍ធម្មតារបស់លោកអ្នក។ នេះគឺជាកិច្ចការមួយដែលយើងនឹងដោះស្រាយជាមួយនិយោជករបស់លោកអ្នក ហើយប្រាកដណាស់ដែលយើងនឹងជម្រាបលោកអ្នកអំពីរឿងនេះ។ ប្រសិនបើលោកអ្នកពុំបានទទួលប្រាក់ Parental Leave Pay របស់ លោកអ្នកពីនិយោជកលោកអ្នកទេ ឬប្រសិនបើលោកអ្នកធ្វើការងារខ្លួនឯង យើងនឹងបង់ប្រាក់ជូនលោកអ្នកដោយផ្ទាល់នៅរាល់ពីរអាទិត្យម្តង។

## របៀបទាមទារParental Leave Pay

១. ដាក់ពាក្យទាមទារ Parental Leave Pay របស់លោកអ្នកឲ្យបានរហូតដល់បីខែ មុនថ្ងៃដែលលោកអ្នករំពឹងថាកូនរបស់លោកអ្នកកើតមក។ លោកអ្នកត្រូវ ទាមទារក្នុងរង្វង់ពេល៥២អាទិត្យ បន្ទាប់ពីថ្ងៃកំណើតនៃកូនរបស់លោកអ្នក ឬការយកកូនមកចិញ្ចឹម។ សូមទាមទារតាមអ៊ីនធើរណិត ឬអញ្ជើញមកមជ្ឈមណ្ឌលផ្តល់កិច្ចបម្រើណាមួយរបស់យើង ហើយទទួលយកពាក្យសុំមួយច្បាប់។ តាមធម្មតា ម្តាយបង្កើត ឬអ្នកមើលថែចម្បងនៃកូនដែលយកមកចិញ្ចឹម ត្រូវដាក់ពាក្យទាមទារនេះ។

២. ដើម្បីចាប់ផ្តើមប្រាក់ជំនួយរបស់លោកអ្នក យើងត្រូវកំណត់សម្រេចការទាមទាររបស់លោកអ្នក ហេតុនេះហើយលោកអ្នកនឹងត្រូវផ្តល់ឲ្យយើងនូវភស្តុតាងនៃកំណើតកូន ឬការយកកូនមកចិញ្ចឹមរបស់លោកអ្នក។ មន្ទីរពេទ្យ ឬឆ្មបរបស់លោកអ្នកនឹងផ្តល់ជូនលោកអ្នកនូវសំបុត្របញ្ជាក់នៃ Newborn Child (ភស្តុតាងនៃកំណើត)។ សូមបញ្ជូនសំបុត្របញ្ជាក់នេះមកយើងវិញឲ្យបានឆាប់បំផុតតាមលទ្ធភាពធ្វើបាន។ លោកអ្នកក៏ត្រូវចុះបញ្ជីកំណើតជាមួយ Births, Deaths and Marriages Registry នៅក្នុងរដ្ឋឬដែនដីរបស់លោកអ្នកដែរ។

## Dad and Partner Pay

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ តទៅ Paid Parental Leave scheme នឹងពង្រីកឲ្យធំទូលាយ ដោយមានប្រាក់ជំនួយថ្មីសម្រាប់ឪពុកដែលធ្វើការ និងដៃគូដទៃទៀតដែលមានសិទ្ធិទទួលបានប្រាក់ជំនួយ។ ប្រសិនបើលោកអ្នកមានសិទ្ធិទទួលបាន លោកអ្នកអាចទទួលប្រាក់ Dad and Partner Pay រហូតដល់ទៅពីរអាទិត្យតាមអត្រានៃ National Minimum Wage។

## សូមឆែកមើលក្រែងលោលោកអ្នកអាចមានសិទ្ធិទទួលបាន Dad and Partner Pay

លោកអ្នកប្រហែលជាអាចទទួលបាន Dad and Partner Pay ប្រសិនបើលោកអ្នកជា:

- ឪពុកបង្កើតរបស់ក្មេង
- ដៃគូរបស់ម្តាយបង្កើត
- ឪពុកម្តាយចិញ្ចឹម ឬដៃគូនៃឪពុកម្តាយចិញ្ចឹម
- ឪពុកម្តាយដែលរៀបចំឲ្យអ្នកដទៃបង្កើតកូនជំនួសខ្លួន ឬដៃគូរបស់ឪពុកម្តាយដែលរៀបចំឲ្យអ្នកដទៃបង្កើតកូនជំនួសខ្លួន ឬ
- ដៃគូភេទដូចគ្នារបស់ម្តាយបង្កើត ឪពុកបង្កើត ឬឪពុកម្តាយចិញ្ចឹម។

ហើយលោកអ្នក:

- ផ្តល់ការមើលថែកូនដែលកើត ឬយកមកចិញ្ចឹមចាប់ពីថ្ងៃទី១ខែមករា ឆ្នាំ២០១៣ តទៅ
- បំពេញតាមតម្រូវការនៃភាពជាពលរដ្ឋរស់នៅក្នុងប្រទេស
- បំពេញតាមតម្រូវការនៃតេស្តការងារដែលតម្រូវឲ្យលោកអ្នកធ្វើការបាន:
    - យ៉ាងហោចណាស់ចំនួន១០ខែ ក្នុងពេល១៣ខែមុនថ្ងៃចាប់ផ្តើមនៃ Dad and Partner Pay  របស់លោកអ្នក
    - យ៉ាងហោចណាស់ចំនួន៣៣០ម៉ោង ក្នុងអំឡុងពេល១០ខែនោះ (គឺត្រឹមតែ១ថ្ងៃប៉ុណ្ណោះ ក្នុង១អាទិត្យ) ដោយពុំមានចន្លោះច្រើនជាងប្រាំបីអាទិត្យ រវាងពីរថ្ងៃធ្វើការបន្តបន្ទាប់គ្នាឡើយ។
- មានប្រាក់ចំណូលត្រូវបង់ពន្ធដារដែលបានកែតម្រូវក្នុងបុគ្គលម្នាក់ៗចំនួន $150 000 ឬតិចជាង ក្នុងឆ្នាំសារពើពន្ធមុនថ្ងៃនៃការទាមទាររបស់លោកអ្នក ឬថ្ងៃដែល Dad and Partner Pay របស់លោកអ្នកចាប់ផ្តើម (មួយណាក៏បានឲ្យតែកើតមានមុន)និង
- កំពុងឈប់សម្រាកពីការងារដោយឥតបានប្រាក់ ឬពុំធ្វើការក្នុងអំឡុងពេល Dad and Partner Pay របស់លោកអ្នក។

**កំណត់សំគាល់:**  លោកអ្នកប្រហែលជានៅតែអាចមានសិទ្ធិទទួលបាន Parental Leave Pay ក្នុងករណីនៃទារកស្លាប់ក្នុងពោះ ឬទារកស្លាប់។

## ពេលដែលលោកអ្នកអាចទទួលបាន Dad and Partner Pay

លោកអ្នកអាចទទួលបានDad and Partner Pay នៅពេលណាមួយក៏បាន នៅក្នុងឆ្នាំទីមួយ ក្រោយពេលកំណើតកូនរបស់លោកអ្នក ឬយកកូនមកចិញ្ចឹម។ លោកអ្នកត្រូវឈប់សម្រាកដោយឥតប្រាក់ការងារ ឬពុំធ្វើការក្នុងអំឡុងពេល Dad and Partner Pay របស់លោកអ្នក (រហូតដល់ទៅពីរអាទិត្យ)។ លោកអ្នកពុំអាចឈប់សម្រាកដោយបានទទួលប្រាក់ការងារឡើយ។

លោកអ្នកអាចជ្រើសរើសពេលចាប់ផ្តើម Dad and Partner Pay period របស់លោកអ្នក។ លោកអ្នកអាចចាប់ផ្តើមពីថ្ងៃដែលកូនរបស់លោកអ្នកកើតមក ឬយកកូនមកចិញ្ចឹម ឬនៅថ្ងៃក្រោយមកទៀត។

## របៀបដែលលោកអ្នកនឹងទទួលបានDad and Partner Pay

យើងនឹងបើកប្រាក់ទៅក្នុងគណនីធនាគាររបស់លោកអ្នកមួយលើក។ និយោជករបស់លោកអ្នកនឹងពុំមានតួនាទីក្នុងការផ្តល់ Dad and Partner Pay ឡើយ។

## របៀបទាមទារ  Dad and Partner Pay

យើងនឹងចាប់ផ្តើមទទួលពាក្យទាមទារចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ តទៅចំពោះទារកដែលកើត ឬការយកកូនមកចិញ្ចឹមដែលបានរំពឹងទុកនៅចំ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។

ដាក់ពាក្យទាមទារ Parental Leave Payរបស់លោកអ្នកឲ្យបានរហូតដល់បីខែមុនថ្ងៃកូនរបស់លោកអ្នកកើត ឬថ្ងៃយកកូនមកចិញ្ចឹម។ លោកអ្នកត្រូវទាមទារក្នុងរង្វង់ពេល៥២អាទិត្យ បន្ទាប់ពីថ្ងៃកំណើតនៃកូនរបស់លោកអ្នក ឬថ្ងៃយកកូនមកចិញ្ចឹម។ លោកអ្នកអាចដាក់ពាក្យទាមទារតាមអ៊ីនធើរណិត ឬអញ្ជើញមកមជ្ឈមណ្ឌលផ្តល់កិច្ចបម្រើណាមួយរបស់យើងក៏បានដែរ។

មុននឹងយើងអាចបើកប្រាក់ជូនលោកអ្នក យើងត្រូវកំណត់សម្រេចពាក្យទាមទាររបស់លោកអ្នក។ លោកអ្នក ឬដៃគូរបស់លោកអ្នកនឹងត្រូវផ្តល់ឲ្យយើងនូវភស្តុតាងនៃកំណើតកូនរបស់លោកអ្នក ឬការយកកូនមកចិញ្ចឹម (និងព័ត៌មានដទៃទៀតណាមួយដែលយើងស្នើសុំ)។ ប្រសិនបើដៃគូរបស់លោកអ្នកគឺជាម្តាយបង្កើតរបស់ក្មេង មធ្យោបាយងាយស្រួលបំផុតដើម្បីផ្តល់ឲ្យយើងនូវភស្តុតាងនៃកំណើតកូន គឺឲ្យម្តាយបង្កើតដាក់សំបុត្របញ្ជាក់ Newborn Child (ភស្តុតាងនៃកំណើត) ដែលលោកអ្នកនឹងទទួលបាននៅមន្ទីរពេទ្យ ឬពីឆ្មបរបស់លោកអ្នកនៅពេលទារកកើតមក។ កំណើតរបស់កូនលោកអ្នកក៏ប្រហែលជាត្រូវការចុះបញ្ជីកំណើត ឬដាក់ពាក្យសុំដើម្បីចុះបញ្ជីកំណើតជាមួយ Births, Deaths and Marriages Registry នៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នកដែរ។

# សិទ្ធិទទួលបាននៅកន្លែងធ្វើការ

គឺជាការសំខាន់ដែលត្រូវដឹងថា Parental Leave Pay និង Dad and Partner Pay ពុំផ្តល់ជូនលោកអ្នកនូវសិទ្ធិដើម្បីឈប់សម្រាកពីការងារឡើយ។ Paid Parental Leave scheme ពុំផ្លាស់ប្តូរសិទ្ធិឈប់សម្រាកណាមួយរបស់លោកអ្នកនៅកន្លែងធ្វើការឡើយ ហើយលោកអ្នកនឹងត្រូវការនិយាយជាមួយនិយោជករបស់លោកអ្នក ដើម្បីរៀបចំឲ្យមានការឈប់សម្រាក។

ប្រសិនបើលោកអ្នកបានធ្វើការឲ្យនិយោជករបស់លោកអ្នកដោយឥតឈប់ក្នុងរយៈពេល១២ខែ ឬច្រើនជាងនេះ លោកអ្នកអាចមានសិទ្ធិទទួលបានការឈប់សម្រាកពីការងារសម្រាប់ឪពុកម្តាយដោយឥតបានប្រាក់បៀវត្សចំនួន១២ខែ នៅក្រោម National Employment Standards ដែលមានក្នុងច្បាប់ *Fair Work Act 2009*។ លោកអ្នកប្រហែលជាអាចបន្ថែមពេលនោះបានរហូតដល់ទៅ១២ខែ ប្រសិនបើនិយោជករបស់លោកអ្នកយល់ព្រម។

លោកអ្នកគួរដឹងអំពីសិទ្ធិទទួលយ៉ាងតិចមួយចំនួនទៀត ប្រសិនបើលោកអ្នកជាផ្នែកនៃគូស្រករ ហើយលោកអ្នកទាំងពីរមានសិទ្ធិទទួលបានការឈប់សម្រាកពីការងារសម្រាប់ឪពុកម្តាយដោយឥតបានប្រាក់។ ឧទាហរណ៍

លោកអ្នក និងដៃគូរបស់លោកអ្នកអាចទទួលយកការឈប់សម្រាកពីការងារឥតបានប្រាក់របស់លោកអ្នកចំនួនបីអាទិត្យ ក្នុងពេលជាមួយគ្នាដោយយកមួយណាក៏បានគឺនៅពេលភ្លាមៗក្រោយពេលកូនកើតមក ឬក្រោយការយកកូនមកចិញ្ចឹម ឬប្រសិនបើនិយោជករបស់ លោកអ្នកយល់ព្រម គឺនៅពេលណាមួយក៏បានក្នុងអំឡុងពេលប្រាំមួយអាទិត្យដំបូង ក្រោយពេលកូនកើតមក ឬក្រោយការយកកូនមកចិញ្ចឹម។ លោកអ្នកក៏មាន សិទ្ធិទទួលបានការឈប់សម្រាកពីការងារសម្រាប់ឪពុកម្ដាយដោយឥតបានប្រាក់ចំនួន២៤ខែ រវាងលោកអ្នកទាំងពីរផងដែរ។

ដើម្បីដឹងច្រើនថែមទៀតអំពីសិទ្ធិទទួលបាននៅកន្លែងធ្វើការរបស់លោកអ្នក សូមបើកមើលនៅត្រង់វិបសាយ fairwork.gov.au ឬទូរស័ព្ទមក Fair Work Ombudsman លេខ 131 394 ។

# ចំពោះព័ត៌មានបន្ថែម

សូមបើកមើលវិបសាយ

- humanservices.gov.au/parentalleavepay
- humanservices.gov.au/dadandpartnerpay
- មជ្ឈមណ្ឌលផ្ដល់កិច្ចបម្រើណាមួយរបស់យើង។

# ការបដិសេធន៍ទទួលខុសត្រូវ

ព័ត៌មាននេះមានភាពត្រឹមត្រូវមកទល់នឹងខែកញ្ញា ឆ្នាំ២០១២។ ប្រសិនបើលោកអ្នកប្រើឯកសារបោះផ្សាយនេះក្រោយកាលបរិច្ឆេទនេះ សូមឆែកមើលជាមួយយើងដើម្បីឲ្យបានដឹងថា ព័ត៌មានពិស្ដារទាំងនោះនៅតែប្រើងដែលឬទេ។

Australian Government
Department of Human Services

# Paid Parental Leave scheme for parents

When you welcome a new child into your family and want to take time off work, it's good to know you can get some financial support to help you.

The Paid Parental Leave scheme helps working parents take time away from work to care for a newborn or recently adopted child. The Australian Government funds the scheme. All types of workers could be eligible, including full-time, part-time, casual, seasonal, contract and self-employed workers.

There are two payments available under the scheme—Parental Leave Pay for a child's primary carer and Dad and Partner Pay which is available for dads or partners (including adopting parents and same-sex couples) from 1 January 2013.

# Parental Leave Pay

As a child's primary carer, you could get up to 18 weeks Parental Leave Pay at the rate of the National Minimum Wage. A primary carer is the person who meets most of the child's physical needs. Parental Leave Pay is taxable.

## Check if you may be eligible for Parental Leave Pay

You may be able to get Parental Leave Pay if you:

- are the primary carer of a newborn or recently adopted child (usually the mother)
- meet residency requirements from the date the child enters your care until the end of your Paid Parental Leave period
- meet the work test, which requires you to have worked for:
  - at least 10 of the 13 months before the birth or adoption
  - at least 330 hours in that 10 month period (just over a day a week), with no more than an eight week gap between two consecutive working days
- had an individual adjusted taxable income of $150 000 or less in the financial year either before the date of birth or adoption, or the date you claim (whichever is earlier), and
- are on leave or not working from the time you become the child's primary carer until the end of your Paid Parental Leave period.

**Note:** you may still be eligible for Parental Leave Pay in the event of a stillbirth or infant death.

## When you can get Parental Leave Pay

Your Paid Parental Leave period (up to 18 weeks) can start from the day your child is born or adopted, or a later date. You can tell us when you'd like it to start when you make a claim. You must take your Parental Leave Pay in one continuous period and it must be fully paid within 52 weeks of the birth or adoption. To get the full 18 weeks of Parental Leave Pay, your start date needs to be within 34 weeks of the birth or adoption.

It is important to know that the date you tell us to start your payment will not be the date your first payment occurs, and for your payments to commence you must provide us with proof of birth or adoption.

You must be on leave or not working from when you become the child's primary carer until the end of your Paid Parental Leave period. You should organise your leave with your employer at least 10 weeks before you want to take it.

## How you'll receive Parental Leave Pay

Even though the government funds Parental Leave Pay, you'll most likely receive it from your employer in your usual pay cycle. This is something we'll work out with your employer, and of course, let you know. If you don't get your Parental Leave Pay from your employer, or if you're self-employed, we will pay you directly in fortnightly instalments.

## How to claim Parental Leave Pay

1. Lodge your claim for Parental Leave Pay up to three months before your child is expected. You must claim within 52 weeks of your child's birth or adoption. Claim online or visit one of our service centres and pick up a form. Usually, the birth mother or the initial primary carer of an adopted child needs to lodge the claim.

2. For your payments to start, we need to finalise your claim so you'll need to give us proof of your child's birth or adoption. A *Newborn Child* (proof of birth) form will be given to you at the hospital or by your midwife. Return this form to us as soon as possible. You also need to register the birth with the Births, Deaths and Marriages Registry in your state or territory.

# Dad and Partner Pay

From 1 January 2013, the Paid Parental Leave scheme will be expanded with a new payment for working dads and other eligible partners. If you're eligible, you can get up to two weeks Dad and Partner Pay at the rate of the National Minimum Wage.

## Check if you may be eligible for Dad and Partner Pay

You may be able to get Dad and Partner Pay if you are the:

- biological father of the child
- partner of the birth mother
- adopting parent or the partner of the adopting parent
- parent in a surrogacy arrangement or the partner of a parent in a surrogacy arrangement, or
- same-sex partner of the birth mother, biological father or the adopting parent.

And, you:

- provide care for a child born or adopted from 1 January 2013
- meet residency requirements
- meet the work test, which requires you to have worked for:
    - at least 10 of the 13 months before the date your Dad and Partner Pay period starts
    - at least 330 hours in that 10 month period (just over a day a week), with no more than an eight week gap between two consecutive working days
- had an individual adjusted taxable income of $150 000 or less in the financial year either before the date of your claim or the date your Dad and Partner Pay period starts (whichever is earlier), and
- are on unpaid leave or not working during your Dad and Partner Pay period.

**Note:** you may still be eligible for Dad and Partner Pay in the event of a stillbirth or infant death.

## When you can get Dad and Partner Pay

You can get Dad and Partner Pay any time in the first year after your child's birth or adoption. You need to be on unpaid leave or not working during your Dad and Partner Pay period (up to two weeks). You can't be on paid leave.

You can choose when your Dad and Partner Pay period will start. It can start from the day your child is born or adopted, or it can start later.

## How you'll receive Dad and Partner Pay

We pay the money into your bank account in one instalment. Your employer will not play a role in providing Dad and Partner Pay.

## How to claim Dad and Partner Pay

We'll start accepting claims from 1 October 2012 for births or adoptions expected on or after 1 January 2013.

Lodge your claim for Dad and Partner Pay up to three months before the expected date of your child's arrival. You must claim within 52 weeks of your child's birth or adoption. Claim online or visit one of our service centres.

Before we can pay you, we need to finalise your claim. You or your partner needs to give us proof of your child's birth or adoption (and any other information we request). If your partner is the birth mother of the child, the easiest way to give us proof of birth is for her to lodge the *Newborn Child* (proof of birth) form she will get in hospital or from her midwife when the baby is born. Also, the child's birth may need to be registered or an application made to register the birth with the Births, Deaths and Marriages Registry in your state or territory.

# Workplace entitlements

It's important to know that Parental Leave Pay and Dad and Partner Pay do not give you an entitlement to leave from work. The Paid Parental Leave scheme does not change any of your workplace leave entitlements and you'll need to talk to your employer to arrange leave.

If you've worked continuously for your employer for 12 months or more, you may be entitled to 12 months unpaid parental leave under the National Employment Standards in the *Fair Work Act 2009.* You may also be able to extend that time by up to 12 months if your employer agrees.

There are some other minimum entitlements you should be aware of if you're part of a couple and you're both entitled to unpaid parental leave. For instance, you and your partner are able to take three weeks of your unpaid leave at the same time either immediately after the birth or adoption or, if your employer agrees, at any time in the first six weeks after your child's birth or adoption. Also, you're entitled to 24 months unpaid parental leave between the two of you.

To learn more about your workplace entitlements, visit **fairwork.gov.au** or call the Fair Work Ombudsman on **131 394**.

# For more information

Visit:

- **humanservices.gov.au/parentalleavepay**
- **humanservices.gov.au/dadandpartnerpay**
- one of our service centres.

## Disclaimer

This information is accurate as at September 2012. If you use this publication after that date, please check with us that the details are current.